ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៤៥/២៤ គ.ជ.ប.ជ

# របាយការណ៍
# ស្តីពី
# ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមករា និងទិសដៅខែកុម្ភៈ ឆ្នាំ២០២៤

## I. ស្ថានភាពទូទៅ

សភាពការណ៍សកលលោក មានការវិវត្តប្រែប្រួលថ្មីៗ ប្លែកៗ គួរឱ្យកត់សម្គាល់ និងមិនអាចប៉ាន់ស្មានបាន មានដូចជា គ្រោះធម្មជាតិ បម្រែបម្រួលអាកាសធាតុ ដែលបាននិងកំពុងគំរាមកំហែង ដល់ការរស់នៅរបស់មនុស្សសត្វលើផែនដី បន្ថែមពីលើសង្គ្រាមកូរ៉េ និងសង្គ្រាមតំបន់ថ្មីៗ នៅបណ្តាប្រទេសមួយចំនួន ដូចជា សង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន អ៊ីស្រាអែលនិងបាឡេស្ទីន បានជះឥទ្ធិពលអវិជ្ជមានធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ច និងសង្គមជាសកល ដែលជាកត្តាជំរុញឱ្យមានលំហូរទេសន្តរប្រវេសន៍។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយបង្កើតនូវបទល្មើសថ្មីៗ នៃទាសភាពសម័យទំនើប និងលេចឡើងនូវការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះ និងជនងាយរងគ្រោះ។

ដោយឡែក នៅប្រទេសកម្ពុជា ឆ្នាំ២០២៣ គឺជាពេលវេលានៃការបោះឆ្នោតជាសកល ដើម្បីរៀបចំរាជរដ្ឋាភិបាលថ្មី នីតិកាលទី៧នៃរដ្ឋសភា។ រាជរដ្ឋាភិបាលថ្មីនេះ បានបន្តការប្តេជ្ញាចិត្ត យកចិត្តទុកដាក់យ៉ាងខ្លាំងលើកិច្ចការពារថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ សុខសុវត្ថិភាពនិងសុខុមាលភាពសង្គមឱ្យបានរឹងមាំ ព្រមទាំងការធានានូវសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញនិងបទបញ្ញត្តិច្បាប់ជាធរមាន។ ឯនៅក្នុងតំបន់ ខិតខំដោះស្រាយបញ្ហា ដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ។

ជាការឆ្លើយតបចំពោះការប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាលអាណត្តិថ្មីបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ មុំទី១ (ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ - អទិភាពទី៤) និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាសេនាធិការ ជូនរាជរដ្ឋាភិបាល ក៏បានការកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនផងដែរចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងរៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ(២០២៤-២០២៨)។

ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងខាងលើ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ បានធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌** បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
- បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្របែលហ្ស៊ិក។

### ខ. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការអប់រំផ្សព្វផ្សាយ

១.១.១. ការអប់រំផ្សព្វផ្សាយ និងវេទិកាសាធារណៈ

នៅក្នុងខែមករា ដើមឆ្នាំ២០២៤នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរ អង្គភាពពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការអនុវត្តគោលនយោបាយ **ភូមិ ឃុំ មានសុវត្ថិភាព** និងការធ្វើវេទិកាសាធារណៈ ផ្សព្វផ្សាយដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **១៣.៥៣០**លើក មានអ្នកចូលរួមសរុបចំនួន **៧៣៤.៩៨០**នាក់ ស្រីចំនួន **៣៧៩.៦៤០**នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន<br>រាជធានី-ខេត្ត | ផ្សព្វផ្សាយ<br>ចំនួន ដង/លើក | ផ្សព្វផ្សាយ<br>ចំនួន មនុស្ស | ផ្សព្វផ្សាយ<br>ចំនួន ស្ត្រី | វេទិកាសាធារណៈ<br>ចំនួន ដង/លើក | វេទិកាសាធារណៈ<br>ចំនួន មនុស្ស | វេទិកាសាធារណៈ<br>ចំនួន ស្ត្រី |
|---|---|---|---|---|---|---|---|
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣០៣ | ៣៣.១២៥ | ១៦.១៣៩ | ៥៥០ | ២០.៩៦៣ | ៩.៧៩៧ |
| | សរុប ក្រសួង ស្ថាប័ន | ៣០៣ លើក | ៣៣.១២៥ នាក់ | ១៦.១៣៩ នាក់ | ៥៥០ លើក | ២០.៩៦៣ នាក់ | ៩.៧៩៧ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | ៩ | ១.០៧៣ | ៤៧៨ |
| ២ | ខេត្តកណ្តាល | ១.៥២៩ | ១២៩.៤៣៧ | ៦៥.៣៧៨ | ១.៦២៦ | ៥៣.៦២៤ | ២៨.១៥៣ |
| ៣ | ខេត្តបាត់ដំបង | ៨៦៣ | ៥០.៦៣១ | ២៦.៤៧១ | ៦១៦ | ២០.៧០៥ | ១១.៩២៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | ខេត្តពោធិ៍សាត់ | ៣១៦ | ៣៣.០២៤ | ១៣.៨៣១ | ១៧៥ | ៦.៨១១ | ៣.១៧៦ |
| ៥ | ខេត្តសៀមរាប | ៤០១ | ៣៣.៤៧១ | ២០.១៣៩ | ១៦៣ | ៥.៤៧០ | ៣.៣៨៤ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧០១ | ២២.៦៤១ | ១១.៩៦៦ | ៣៦០ | ៩.៧០៣ | ៥.១៣៥ |
| ៧ | ខេត្តកំពង់ចាម | ១.៨៩៣ | ១២៤.២៣៥ | ៦០.៥១៩ | ៥ | ៣១៧ | ១០៤ |
| ៨ | ខេត្តព្រះសីហនុ | ៩៣ | ៥.៥៩៤ | ២.៣២៧ | ២ | ៩៤ | ២៩ |
| ៩ | ខេត្តព្រះវិហារ | ២០ | ២.៤២៩ | ១.៥០៨ | | | |
| ១០ | ខេត្តស្វាយរៀង | ៤៤៦ | ២៧.១២០ | ១៣.៤១៥ | ៣៩៦ | ១៤.៧៥៧ | ៨.៣៣៩ |
| ១១ | ខេត្តប៉ៃលិន | ៥៩ | ១.៨៦៣ | ៥៤៦ | ៣៩ | ១.៥៤៤ | ៣៩៣ |
| ១២ | ខេត្តកោះកុង | | | | ១១៧ | ២.៦៦០ | ១.២៥៧ |
| ១៣ | ខេត្តកំពត | ៣០ | ៤៥០ | ២៥០ | ១៥ | ៥៦០ | ៣៥០ |
| ១៤ | ខេត្តកំពង់ធំ | ៤៥៦ | ៣២.៨៣០ | ១៩.២០៧ | ១៣៤ | ៥.៤៨៣ | ៣.៤៨០ |
| ១៥ | ខេត្តតាកែវ | ៣៦៧ | ១៤.៣០៧ | ៧.៨០០ | ៩៦ | ៣.៤៥០ | ២.០៣១ |
| ១៦ | ខេត្តក្រចេះ | ២៥ | ៨៨១ | ៤៩៥ | | | |
| ១៧ | ខេត្តកែប | ២៧ | ៥.០៩៥ | ២.៣០៦ | ៣៦ | ១.៥១២ | ៦៩៥ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ២៩៥ | ២៨.៦៦៩ | ១៥.៦៦៤ | ២២ | ១.៥៣៦ | ៧២១ |
| ២២ | ខេត្តត្បូងឃ្មុំ | ៩៨ | ១.៤៦៤ | ៧១២ | ២ | ៥៤ | ២២ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៦៨៨ | ១២.៧៨៧ | ៧.៥៧២ | ២០៩ | ៥.៩៦១ | ៣.៥៦៨ |
| ២៤ | ខេត្តឧត្តរមានជ័យ | ១៨៧ | ១២.៩១៨ | ៧.៣៥៥ | ៥៧ | ២.១៩៩ | ១.៣៤៨ |
| ២៥ | ខេត្តមណ្ឌលគិរី | ១០៣ | ៣.៤៩០ | ១.៦៧៤ | ១ | ៤៣ | ១៧ |
| សរុប រាជធានី-ខេត្ត | | ៨.៥៩៧ | ៥៤៣.៣៣៦ | ២៧៩.១៣៥ | ៤.០៨០ | ១៣៧.៥៥៦ | ៧៤.៥៦៩ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ១៣.៥៣០ លើក | | ចំនួនមនុស្ស ៧៣៤.៩៨០ នាក់ | | ចំនួនស្ត្រី ៣៧៩.៦៤០ នាក់ | |

### ១.១.២. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តសៀមរាប៖ អង្គការមូលនិធិអេ២១** បានធ្វើការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ អំពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ នៅតាមសហគមន៍ បានចំនួន **១៦លើក** មានអ្នកចូលរួមសរុប **៦.៩៧៨**នាក់ ស្រី **៣.៤០២**នាក់។
- **ខេត្តបន្ទាយមានជ័យ៖ អង្គការសាម៉ារីតាន់ភឺស** បានផ្ដល់ការអប់រំសហគមន៍អំពីការចំណាកស្រុកសុវត្ថិភាព និងអប់រំសហគមន៍អំពីហិង្សាយេនឌ័រ បានចំនួន២១៣ នាក់ ស្រី៥៩នាក់ កុមារា១៣នាក់ កុមារី១១នាក់ ចំនួន៣៣លើក។

### ១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តបាត់ដំបង៖**
  - **មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** បានចូលរួមជាមួយមណ្ឌលទទួលពលករកំរៀង ចុះអប់រំអំពី "ការការពារខ្លួនពីការឆ្លងមេរោគអេដស៍ និងផលប៉ះពាល់ពីការប្រើប្រាស់គ្រឿងញៀន នៅមូលដ្ឋាន និងសុវត្ថិភាពទេសន្តរប្រវេសន៍" ចំនួន០៦លើក មានអ្នកចូលរួមចំនួន **១២៩**នាក់ ស្រី**៩៥**នាក់។
  - **អង្គការសាម៉ារីតាន់ភឺស** ចុះជ្រើសរើសអ្នកស្ម័គ្រចិត្តភូមិ និងយុវជនស្ម័គ្រចិត្តក្នុងការផ្សព្វផ្សាយបន្តនូវមេរៀនពីការចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស និងអំពើហិង្សាទាក់ទង នឹងយេនឌ័រតាមខ្នងផ្ទះ និងសាលារៀន អ្នកចូលរួម **៧៨**នាក់ ស្រី **១១**នាក់ អនីតិជន **៥៣**នាក់។

- **ខេត្តតាកែវ៖ លេខាធិការដ្ឋាន គ.ខ.ប.ជ** បានសហការជាមួយក្រុមគ្រូពេទ្យប្រទេសបារាំង ចុះពិនិត្យសុខភាព និងចែកអំណោយជូនប្រជាពលរដ្ឋ នៅឃុំពេជសារ ស្រុកកោះអណ្តែត និងស្រុកគិរីវង់ ចំនួន ៤៩៣គ្រួសារ ព្រមទាំងបានបញ្ជ្រាបសារអប់រំអំពី ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយប្រថុយប្រថានជូនពលរដ្ឋក្នុងពេលនោះផងដែរ។
- **ខេត្តកំពង់ចាម៖**
  - **រដ្ឋបាលក្រុង ស្រុកទាំង១០** ៖បានអប់រំផ្សព្វផ្សាយទៅតាមរយៈការប្រជុំគ.ស.ន.កនិងគ.ក.ន.កពាក់ព័ន្ធទៅនឹងការចាប់រំលោភសេពសន្ថៈទៅលើស្ត្រី និងកុមារ និងអំពីបញ្ហាចំណាកស្រុកទៅការងារធ្វើចៀសវាងការឆបោកតាមរយៈមេខ្យល់ ។
  - **ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី** នៃស្នងការដ្ឋាននគរបាលខេត្ត បានចុះផ្សព្វផ្សាយ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកស្តីពីការកំណត់បែបបទ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ជាមួយជនបរទេស ជៀសវាងការចាញ់បោកជនឆបោក ការកេងប្រវ័ញ្ចកំលាំពលកម្ម និងការជួញដូរមនុស្ស ការធ្វើអាជីវកម្ម និងអំពើហឹង្សាផ្សេងៗនៅក្រៅប្រទេស បានចំនួន ០៧លើក មានអ្នកចូលរួម **១៧៥**នាក់ ស្រី **៨៦**នាក់។
- **ខេត្តកណ្តាល៖ មន្ទីរអប់រំ យុវជន និងកីឡា** បានបញ្ជ្រាបការផ្សព្វផ្សាយអំពើការជួញដូរមនុស្សតាមរយៈកិច្ចប្រជុំបូកសរុបការងារ និងកម្មវិធីផ្សេងៗ ព្រមទាំងណែនាំមន្ត្រីរាជការនៃមន្ទីរអប់រំយុវជននិងកីឡា មន្ត្រីជាប់កិច្ចសន្យាឱ្យផ្សព្វផ្សាយបន្តដល់សិស្សានុសិស្ស នៅរៀងរាល់ពេលគោរពទង់ជាតិព្រឹកថ្ងៃច័ន្ទ ចំនួន ០៣លើក មានមន្ត្រីពាក់ព័ន្ធចូលរួម **២៤៧**នាក់ ស្រី**៧៨**នាក់។
- **ខេត្តត្បូងឃ្មុំ៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** ក្រុមការងារអធិការកិច្ចបានចុះសម្របសម្រួលនិងដោះស្រាយវិវាទការងាររវាងកម្មសំណង់ និងនិយោជន(ការដ្ឋានសំណង់ គីមពិច) នៅស្រុកពញាក្រែក និងចុះអធិការកិច្ចពិសេសនៅក្រុមហ៊ុន ណឹមម៉េងប្រូកូយ៉ាញដេនឈរ៍ ឯ.ក ស្រុកតំបែរ ឆ្លៀតឱកាសក្នុងពេលនោះក្រុមការងារអធិការកិច្ចបានផ្សព្វផ្សាយបន្ថែមស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់កម្មករនិយោជិត សរុបចំនួន **៦៤**នាក់ ស្រី **១៣**នាក់។
- **ខេត្តកំពង់ឆ្នាំង៖**
  - **មន្ទីរអប់រំ យុវជន និងកីឡា** បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈកិច្ចតាមប្រព័ន្ធអនឡាញ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងសិស្សានុសិស្សនៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនសាលាផងដែរ ចំនួន ០៨លើក។
  - **មន្ទីរកិច្ចការនារី** បានចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងការធ្វើចំណាកស្រុកដោយខុសច្បាប់ និងការជួញដូរមនុស្ស ខួបលើកទី១៧ ក្រោមប្រធានបទ **បច្ចេកវិទ្យាជាមធ្យោបាយដើម្បីអភិវឌ្ឍន៍ជាតិមិនមែនដើម្បីជួញដូរមនុស្ស** មានអ្នកចូលរួមសរុប **១២៦**នាក់ ស្រី **៧០**នាក់។
  - **ស្រុកទឹកផុស** បានផ្សព្វផ្សាយច្បាប់ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំគណៈបញ្ជាការឯកភាព កិច្ចប្រជុំ គ.ក.ស.ក និងកិច្ចប្រជុំសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចំនួន ០៣លើក មានអ្នកចូលសរុបចំនួន **៥៨**នាក់ ស្រី **០៨**នាក់។
- **ខេត្តកំពត៖** បានផ្សព្វផ្សាយការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំ គ.ក.ស.ក និងកិច្ចប្រជុំ គ.ក.ន.ក នៅស្រុកដងទង់ និងស្រុកឈូក ចំនួន **២៧**លើក អ្នកចូលរួមសរុប **១៣០**នាក់ ស្រី **៧០**នាក់។

- **ខេត្តប៉ៃលិនៈ មន្ទីរអប់រំ យុវជន និងកីឡា** បានបញ្ជ្រាបអំពីការបង្ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ ការចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់ ការឆបោកតាមប្រព័ន្ធអនឡាញ ក្នុងកិច្ចប្រជុំកែសម្រួលអនុក្រឹត្យលេខ ៨៨អនក្រ.បក ស្តីពី ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងកំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩ និងនៅក្នុងពិធីចែកប័ណ្ណសរសើរដល់សិស្សឆ្នើមប្រចាំឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាល័យ ហ៊ុន សែន ក្រុងទេពនិមិត្ត មានអ្នកចូលរួមប្រមាណ ៣៥០នាក់ ស្រី២០០នាក់។
- **ខេត្តបន្ទាយមានជ័យៈ**
  - **អង្គការតំណក់ទឹកសាខាប៉ោយប៉ែតៈ**
    - ប្រជុំលើកកម្ពស់ការយល់ដឹងដល់ក្រុមយុវជន និងគ្រួសារ ស្តីពី ចំណាកស្រុកប្រកប ដោយសុវត្ថិភាព បញ្ជ្រាបពីសារៈសំខាន់នៃការសិក្សារបស់កូន អ្នកចូលរួម៣៩នាក់ ស្រី២៣នាក់។
    - បានចុះធ្វើបណ្ណាល័យចល័ត ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ សិស្សានុសិស្ស និងកុមារតូច បានចំនួន១០១នាក់ ស្រី៤៥នាក់។
  - **អង្គការអន្តរជាតិទេសន្តរប្រវេសន៍ IOM** បានធ្វើការផ្តល់វគ្គតម្រង់ទិស ស្តីពីធ្វើការសម្រេចចិត្តដែលប្រកបដោយសុវត្ថិភាពដល់ពលករ សុរប ៣២៨នាក់ ស្រី១២៧នាក់។

### ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន ១.០៣៦ដង។
- **ខេត្តសៀមរាបៈ** មន្ទីរព័ត៌មាន ផ្សព្វផ្សាយតាមវិទ្យុចំនួន ១៧៩លើក។
- **ខេត្តព្រៃវែងៈ** មន្ទីរព័ត៌មាន ផ្សព្វផ្សាយតាមវិទ្យុចំនួន ៥០លើក។
- **ខេត្តត្បូងឃ្មុំៈ** មន្ទីរព័ត៌មាន ផ្សព្វផ្សាយតាមវិទ្យុចំនួន ៨០លើក។
- **ខេត្តប៉ៃលិនៈ** ផ្សព្វផ្សាយតាមវិទ្យុចំនួន ០៨លើក។

### ១.៣. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ (IEC)

- **ខេត្តសៀមរាបៈ រដ្ឋបាលស្រុកពួក** បានចែកខិតប័ណ្ណអំពីការធ្វើចំណាកស្រុក ចំនួន **២.៧៥០**ខិតប័ណ្ណ។
- **ខេត្តបន្ទាយមានជ័យៈ**
  - **ក្រុមការងារ គ.ខ.ប.ជៈ** បានរៀបចំចងបដាពាក្យស្លោកពាក់ព័ន្ធនឹង ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅបរិវេណស្ទួនមានជ័យ ចំនួន០៦បដា។
  - **អង្គការសាម៉ារីតាន់ភឺស** បានចែកខិត្តប័ណ្ណស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ពលករត្រឡប់ពីក្រៅប្រទេសចំនួន ៥៣៧នាក់ ស្រី១៦៧នាក់ កុមារ២៤នាក់។

### ១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
  - ឯកឧត្តម ឧត្តមសេនីយ៍ត្រី **តៃ សុថារេត** អគ្គលេខាធិការរង បានអញ្ជើញចូលរួមធ្វើជាវាគ្មិនកិត្តិយស នៅក្នុងកម្មវិធីសន្ទនាមតិ "ជីវិតយើង សង្គមយើង" ដោយពិភាក្សាលើប្រធានបទស្តីពី "រួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ" នៅក្នុងកម្មវិធីវិទ្យុជាតិ និងវិទ្យុវត្តភ្នំ ព្រមទាំងអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមសាកសួរ និងពិភាក្សាតាមរយៈទូរស័ព្ទផងដែរ។
- **ខេត្តកំពង់ចាមៈ ក្រុមការងារជំនាញនៃ គ.ខ.ប.ជ** បានចូលរួមធ្វើជាវាគ្មិននៅវិទ្យុ ក្រោមប្រធានបទការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងប្រសិទ្ធភាពនៃការទប់ស្កាត់ចំណាកស្រុកខុសច្បាប់ ចំនួន ០៣លើក។
- **ខេត្តបាត់ដំបងៈ** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនកិត្តិយសនៅស្ថានីយវិទ្យុជាតិកម្ពុជា ក្រោមប្រធានបទ "**សុវត្ថិភាពស្ត្រីក្នុងការធ្វើចំណាកស្រុក**" ០១លើក។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរ ចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងជាប់ការទាក់ទងសរុបចំនួន ១៨២.៤៦៦នាក់ (ស្រី៨០.៧៣៩នាក់) អនីតិជន ៣.៤៤៨នាក់(ស្រី ១.២៤១នាក់)៖
  - ស្របច្បាប់ ចំនួន ១៤១.៧០៩នាក់ (ស្រី ៦៤.៩៦៨នាក់) អនីតិជន ៣២៣នាក់ (ស្រី ១០០នាក់)
  - មិនស្របច្បាប់ចំនួន ៤០.០៨១នាក់(ស្រី១៥.៤៨២នាក់) អនីតិជន ៣.០១១នាក់(ស្រី១.១១០នាក់)
  - ជាប់ការទាក់ទងចំនួន ៦៧៦នាក់(ស្រី ២៨៩នាក់) អនីតិជន ១៣៥នាក់(ស្រី៣១នាក់)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៤.២០៥នាក់ (ស្រី ៦.៣៨០នាក់) អនីតិជន ១៥៣នាក់(ស្រី ៨៩នាក់)។

### ២.២. វិធានការជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តកោះកុង តាកែវ និងខេត្តព្រៃវែង បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ០៥លើក។

### ២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ចំនួន ១៧៩នាក់(ស្រី១៩នាក់) មាន ១៧សញ្ជាតិ និងវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូលតែមួយចំនួន ១៦៥នាក់(ស្រី១០នាក់) បានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ រៀបការទៅរស់នៅប្រទេសចិនចំនួន ០៤នាក់។

## ៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្ដាញម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ចំនួន ១.១៣៣នាក់ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## ១. ការងារអនុវត្តច្បាប់

### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៩ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន ២២នាក់(ស្រី០១នាក់)។

សង្គ្រោះជនរងគ្រោះ ចំនួន ២២នាក់(ស្រី ២១នាក់) មាន: អាយុក្រោម១៥ឆ្នាំ ១៩នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០២នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៤នាក់ និងគ្រួសារចំនួន ១៨នាក់)។ ក្នុងនោះចែកជា៖

- **ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ០១ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៤នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ០២នាក់ (ស្រី០១នាក់) អាយុ១៨ឆ្នាំឡើង និងបានប្រគល់ឱ្យមន្ទីរសង្គមកិច្ច។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ(ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -អំពើលក់-ដូរមនុស្សដោយមានគោលដៅ | ០១ | ០២(០១) | ០៤ |
| *សរុប* | *០១ ករណី* | *០២(០១)នាក់* | *០៤ នាក់* |

❖ **ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១៨ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៨នាក់(ស្រី០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ២០នាក់(ស្រី ២០នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ១៩នាក់ អាយុ១៥-១៧ឆ្នាំ០១នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច០២នាក់ និងគ្រួសារ ១៨នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ(ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០១ | ០២(០២) | ០១ |
| -រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១(០១) | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៣ | ១៣(១៣) | ១៣ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៤(០៤) | ០៣ |
| *សរុប* | *១៨ ករណី* | *២០(២០)នាក់* | *១៨ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

**១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

▪ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានទទួលចំនួន ៥៣នាក់ (ស្រី៥២នាក់ កុមារី ០១នាក់) មកពីប្រទេសចិន ៥២នាក់ និងប្រទេសម៉ាឡេស៊ី ០១នាក់(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ៤៩នាក់ ងាយរងគ្រោះ ០២នាក់ និងជនមានវិបល្លាសស្មារតី ០២នាក់) បានសម្ភាសន៍កំណត់អត្តសញ្ញាណបឋម ដើម្បីផ្តល់សេវាសមស្របចំនួន ៤៩នាក់(កុមារី០១នាក់) និងបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។

- **មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពករចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃ ចំនួន ៥៩៣នាក់ បានកំណត់អត្តសញ្ញាណបឋមរកឃើញករណីងាយរងគ្រោះ ០៥នាក់ ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ០៤នាក់(ស្រី០១នាក់) និងបានបញ្ជូនទៅទទួលសេវានៅអង្គការរតនៈអ៊ីនជីនេសិនណល ០៣នាក់ បញ្ជូនទៅសហគមន៍ ០១នាក់។

*ដោយឡែក៖* ជនរងគ្រោះបានទទួលពី សមត្ថកិច្ចនៅក្នុងស្រុកចំនួន ៦៦នាក់(ស្រី០២នាក់) ជាជនបរទេស មាន ០៦សញ្ជាតិរួមមាន៖ បង់ក្លាដេស៥១នាក់ ចិន០៣នាក់ ឥណ្ឌា០៥នាក់ វៀតណាម០៥នាក់ ឥណ្ឌូនេស៊ី០១នាក់ និងស្រីលង្កា០១នាក់ (ជាករណីជួញដូរកម្លាំងពលកម្ម)។

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់ពីប្រទេសចិនចំនួន ២៤នាក់(ស្រី)។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ២១នាក់ ស្នាក់នៅដោយខុសច្បាប់ ០៣នាក់។

- ខេត្តកោះកុង៖ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១៣លើក មនុស្សចំនួន ៣០នាក់ ស្រី០៥នាក់។
- ខេត្តស្វាយរៀង៖ ស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរពីសមត្ថកិច្ចវៀតណាម ចំនួន ០៤លើក មនុស្សចំនួន ៥៥នាក់(ស្រី៣៥នាក់ កុមារ ៣៤នាក់)។

## ២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា នៅអង្គការការការពារសិទ្ធិកុម្ពុជា ហាការ តេនៈអ៊ីនធើណេសិនណល IJM CWCC អេ២១ ចាប់ដៃ អាដហុក និងមជ្ឈមណ្ឌលថែទាំនិងស្តារនីតិសម្បទាជនវិបល្លាសស្មារតី សរុបចំនួន ១១៩នាក់ (ស្ត្រី ៥៤នាក់ កុមារី ០១នាក់)។

## ៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅសហគមន៍វិញចំនួន ០១នាក់(ស្រី)។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ១. ការងារបណ្តុះបណ្តាល

ក្រសួង ស្ថាប័ន បានសហការជាមួយស្ថានទូត មន្ទីរពាក់ព័ន្ធ ក្រុមហ៊ុន សហគ្រាស អង្គការដៃគូពាក់ព័ន្ធមាន៖ អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី អង្គការហាការ អង្គការ IOM និង ILO បើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្ត ស្តីពី៖
- ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការកំណត់អត្តសញ្ញាណជនរងគ្រោះ។
- ប្រធានបទពាក់ព័ន្ធនឹងសុវត្ថិភាពអ៊ីនធឺណិត និងកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។

| ល.រ | សកម្មភាពរបស់ថ្នាក់ជាតិ | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (មណ្ឌលគិរី) | ០១ | ៥១ | ២៤ |
| | សរុបសកម្មភាពថ្នាក់ជាតិ | ០១ | ៥១ | ២៤ |
| ល.រ | សកម្មភាពរបស់ថ្នាក់ក្រោមជាតិ | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
| ១ | ខេត្តស្វាយរៀង | ០៧ | ១៤៣ | ៧៤ |
| ២ | ខេត្តព្រៃវែង | ០១ | ២៨ | ០០ |
| ៣ | ខេត្តបន្ទាយមានជ័យ | ០៣ | ២៨៨ | ១៥៩ |
| ៤ | ខេត្តបាត់ដំបង | ០១ | ៥១ | ១៣ |
| ៥ | ខេត្តស្ទឹងត្រែង | ០១ | ៤៤ | ០៤ |
| | **សរុបសកម្មភាពថ្នាក់ក្រោមជាតិ** | **១៣** | **៥៥៤** | **២៥០** |
| | ***សរុបរួម*** | ***១៤*** | ***៦០៥*** | ***២៧៤*** |

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំ៖ ១.រកធាតុចូលត្រៀមរបាយការណ៍សន្និបាតប្រចាំឆ្នាំ របស់ក្រសួងមហាផ្ទៃ។ ២.ពិគ្រោះយោបល់ ផ្តល់ព័ត៌មានដែលជាធាតុចូលដល់របាយការណ៍ ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ របស់ក្រសួងការបរទេស នៃសហរដ្ឋអាមេរិក ចំនួន០២លើក។ ៣.បច្ចេកទេសជាមួយក្រុមគ្រូបង្គោល ដើម្បីពិនិត្យ និងរៀបចំកែសម្រួល សៀវភៅគោលបង្រៀនសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពី គោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ៤.ពង្រឹងរបៀបរបបការងារ មន្ត្រីនគរបាលជាតិ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។

- **ខេត្តបន្ទាយមានជ័យ៖ អង្គការអន្តរជាតិទេសន្តរប្រវេសន៍កម្ពុជា** បានសហការជាមួយរដ្ឋបាល និង លេខាធិការដ្ឋានអាស៊ាន បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីការកែលម្អ និងតាមដាន ការឃ្លាំមើលសុខភាពតាមព្រំដែននៃបណ្តាប្រទេសក្នុងតំបន់អាស៊ាន តាមប្រព័ន្ធហ្សូម ក្នុងគោលបំណង ចែករំលែកបទពិសោធន៍ការងារឆ្លើយតប និងបញ្ហាសុខភាពសម្រាប់ជនទេសន្តរប្រវេសន៍ នៃបណ្តា ប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក អ្នកចូលរួម ៨៥នាក់ ស្រី ៣៥នាក់។

**២. ការទទួលជួបពិភាក្សាការងារ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួង មហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបសំណេះសំណាល និងពិភាក្សាការងារជាមួយ កិច្ចពិភាក្សាជាមួយគណៈប្រតិភូអង្គការ សហប្រជាជាតិ មានឯកឧត្តម Joseph Scheuer តំណាង អង្គ ការសហប្រជាជាតិប្រចាំកម្ពុជា លោកស្រី Roueida El Hage តំណាងឧត្តមស្នងការសិទ្ធិមនុស្ស OHCHR នៅកម្ពុជា លោកស្រី Alissa Chaker តំណាងអង្គការ UNDP ប្រចាំកម្ពុជា លោកស្រី Kristin Parco ប្រធានបេសកកម្មអង្គការ IOM កម្ពុជា។
- **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារជំនាញ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយតំណាងអង្គការ ជីវិតថ្លៃថ្នូរ លើការអនុវត្តន៍គម្រោងបង្ការការជួញដូរមនុស្ស តាមរយៈការលើកកម្ពស់ ជីវភាពរស់នៅរបស់ ប្រជាជនដែលងាយរងគ្រោះ និងជនចំណាកស្រុកត្រឡប់មកវិញ នៅស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ មានអ្នកចូលរួម ១១នាក់ ស្រី០៤នាក់។
- **ខេត្តសៀមរាប៖**
  - ក្រុមការងារជំនាញ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយតំណាងអង្គការជីវិតថ្លៃថ្នូរ លើការអនុវត្ត គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងខេត្តសៀមរាប មានអ្នកចូលរួម ០៦នាក់ ស្រី ០២នាក់។
  - ក្រុមការងារជំនួយការលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយតំណាង អង្គការមូល និធិអេ២១ ស្តីពី ការរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងមត្ថភាពទៅដល់មន្ត្រីនគរបាលយុត្តិធម៌ និងក្រុម ការងារ នៅថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់។
- **ខេត្តកោះកុង៖** ក្រុមការងារជំនាញ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយអង្គការជីវិតថ្លៃថ្នូរ និង អង្គការវីនរ៉ក់អន្តរជាតិ ស្តីពី ការបន្តការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងខេត្តកោះកុង។

**គ. ការងារសម្របសម្រួល**

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស ចំនួន **៥២**លើក មានអ្នកចូលរួមសរុប **១.៤៥៩**នាក់ (ស្រី **៤១៩**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១២**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **៤០**លើក។**(ឧបសម្ព័ន្ធ១)**

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្ត ទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរ ជាតិផងដែរ។
- យើងមានច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិ វិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅ នឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និង លិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។

- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅឆ្នាំ ២០២៤

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្តែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការជួញដូរទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៨. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

៩. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១០. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ................ខែ.........ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ សរុបចំនួន ៥២លើក មនុស្សចំនួន ១.៤៥៩នាក់ (ស្រី ៤១៩នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.បានអញ្ជើញចូលរួម ជាអធិបតីក្នុង៖<br>- កិច្ចប្រជុំថ្នាក់ដឹកនាំ និងសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ លើកទី១ នីតិកាលទី៧ នៃរដ្ឋសភា នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ពិធីបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅបន្ត របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- កិច្ចប្រជុំរកធាតុចូលត្រៀមរបាយការណ៍សន្និបាតប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ផ្តល់ ព័ត៌មានដែលជាធាតុចូលដល់របាយការណ៍ ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំរបស់ក្រសួងការបរទេស នៃសហរដ្ឋអាមេរិក ចំនួន ០២លើក ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ មានអ្នកចូលរួម ៤១នាក់ ស្រី ១០នាក់។<br>- អមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារបន្ត របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ២០ច្បាប់ លិខិតចូល ១៤ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២៤ច្បាប់ លិខិតចូល ២០ច្បាប់។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ៥៥ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ១៦សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ៤២ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម កិច្ចប្រជុំប្រជុំថ្នាក់ដឹកនាំ និងសមាជិកនៃ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ |

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - បានចូលរួមជាគ្រូឧទ្ទេសវគ្គបណ្ដុះបណ្ដាល ស្ដីពី ការផ្ដល់ប្រឹក្សាយោបល់ពាក់ព័ន្ធនិងអំពើហិង្សា និងការរំលោភបំពាន់គ្រប់ទម្រង់ដល់មន្ត្រីនគរបាល និងប្រជាការពារ នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដោយមានសិក្ខាកាមចូលរួមចំនួន ៣២នាក់ ស្រី០៧នាក់។
  - បានចូលរួមជាគ្រូឧទ្ទេស វគ្គបណ្ដុះបណ្ដាល ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ ជូ **ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តមណ្ឌលគីរី។
  - បានចូលរួមជាគ្រូឧទ្ទេស វគ្គបណ្ដុះបណ្ដាល ស្ដីពីការ ប្រឹក្សាយោបល់ពាក់ព័ន្ធ អំពើហឹង្សា និងការរំលោភបំពានគ្រប់ទម្រង់ ដល់មន្ត្រីនគរបាលប៉ុស្ដិ៍ និងប្រជាការពារ ស្រុកសៀមបូក និងស្រុកសេសាន្ត ខេត្តស្ទឹងត្រែង។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម៖ ១.កិច្ចប្រជុំ បច្ចេកទេស ជាមួយក្រុមគ្រូបង្គោលដើម្បីពិនិត្យនិងរៀបចំកែសម្រួល សៀវភៅគោលបង្រៀនសម្រាប់វគ្គបណ្ដុះបណ្ដាលស្ដីពី គោលការណែនាំស្ដីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គជ.ប.ជ.។ ២.កិច្ចប្រជុំពិនិត្យពិភាក្សា លើសេចក្ដីព្រាង អនុស្សរណៈនៃការយោគយល់ស្ដីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាង ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ក្រោមអធិបតីភាព ឯកឧត្តម **អ៊ូច ចាន់ណូរ៉ា** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ មានអ្នកចូលរួម ២៤នាក់ ស្រី០១នាក់។ ៣.កិច្ចប្រជុំថ្នាក់ដឹកនាំ និងសមាជិកនៃ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ នៅទីស្ដីការក្រសួងមហាផ្ទៃ។
- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**
  - បានចូលរួមកិច្ចប្រជុំជាមួយតំណាងអង្គការ IJM ស្ដីពីការរៀបចំផែនការបណ្ដុះបណ្ដាលស្ដីពី បែបបទ និងនីតិវិធី នៃកាកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្របសម្រាប់ខេត្តកោះកុង បាត់ដំបង និងបន្ទាយមានជ័យ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - បានចូលរួមកិច្ចប្រជុំជាមួយក្រុមគ្រូឧទ្ទេស ដើម្បីកែសម្រួលមេរៀនស្ដីពី បែបបទ និងនីតិវិធី នៃកាកំណត់អត្តសញ្ញាណជនរងគ្រោះដោយ អំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រម ក្រោមការដឹកនាំរបស់ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - បានចូលរួមបើកវគ្គបណ្ដុះបណ្ដាលស្ដីពី បែបបទ និងនីតិវិធី នៃកាកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដើម្បី ផ្ដល់សេវាសមស្រម នៅខេត្តមណ្ឌលគិរី ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
  - បានចូលរួមកិច្ចប្រជុំពិភាក្សាស្ដីពី គោលនយោបាយរបស់ប្រទេសបញ្ជូន ក្នុងការគាំទ្រដល់សិទ្ធិទទួលបានរបបសន្តិសុខសង្គម របស់ជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយ Mekong Migration Network ( MMN ) សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់ស្រី និងកុមារ ( LSCW ) នៅសណ្ឋាគារ Sunway ភ្នំពេញ។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ **សុថារេត** អគ្គលេខាធិការរង៖ ១.កិច្ចប្រជុំពិនិត្យ និងផ្តល់ធាតុចូលចុងក្រោយសម្រាប់របាយការណ៍ ពិនិត្យជាសកលតាមកាលកំណត់(UPR) ជុំទី៤ របស់កម្ពុជាជូនអង្គការសហប្រជាជាតិ ក្រោមអធិបតីភាព ឯកឧត្តម **កែវ រ៉េមី** ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី មានអ្នកចូលរួម **៦៥**នាក់ ស្រី **១១**នាក់។ ២.ប្រជុំបច្ចេកទេស ជាមួយក្រុមគ្រូបង្គោល ដើម្បីពិនិត្យនិងរៀបចំកែសម្រួលសៀវភៅគោលបង្រៀនសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី គោលការណែនាំ ស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជ.ប.ជ.។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៤០ លើក អ្នកចូលរួមសរុបចំនួន ១.៣០១នាក់ (ស្រី ៣៩០នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែ ០១លើក អ្នកចូលរួម **៣២**នាក់ ស្រី**២១**នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែសីហា ០៤លើក អ្នកចូលរួម **១០០**នាក់ ស្រី**៤៥**នាក់។ |
| **ខេត្តត្បូងឃ្មុំ** | - មន្ត្រីជំនាញ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចូលរួមកិច្ចប្រជុំស្តីពី ការធ្វើផែនការបណ្តុះបណ្តាលសារាចរណែនាំលេខ ០១១ ជាមួយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និងបានជួបប្រជុំជាមួយការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ដើម្បីសិក្សាពីការអនុវត្តការងារបញ្ហាប្រឈម និងដំណោះស្រាយការងារទាក់ទងទៅនឹងអំពើជួញដូរមនុស្ស។ |
| **ខេត្តព្រៃវែង** | - បញ្ជូនសិក្ខាកាមចូលរួមវគ្គបំប៉នជំនាញស្រាវជ្រាវ ស៊ើបអង្កេតកំណត់អត្តសញ្ញាណជនសង្ស័យ(ផ្នែកព្រហ្មទណ្ឌនិងជួញដូរពលកម្ម) នៅក្រៅប្រទេស ០១លើក។ |
| **ខេត្តសៀមរាប** | - គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការសកម្មភាព ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានអ្នកចូលរួម **២៥០**នាក់ ស្រី**៩៩**នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ ចំនួន ០៨លើក អ្នកចូលរួមចំនួន **២០៨**នាក់ ស្រី**៨៧**នាក់។<br>- ក្រុមការងារ ក.ស្រ.ប.ជ បានចូលរួមប្រជុំត្រីមាសទី៤ ស្តីពីកិច្ចសហការក្នុងការអនុវត្តការគ្រប់គ្រងករណីរួមគ្នា រវាងអង្គការដៃគូរ ដើម្បីកិច្ចការពារកុមារ (3PC) ជាមួយការិយាល័យសង្គមកិច្ចនិងសុខមាលភាពសង្គម និងរដ្ឋបាលក្រុង ស្រុក ០១លើក ។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ ០១លើក។ |
| **ខេត្តស្វាយរៀង** | - លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ២០២៣ និងទិសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព លោកជំទាវ **យក់ ស៊ីណាត** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ មានអ្នកចូលរួមសរុប **៥៧**នាក់ ស្រី **២៥**នាក់។<br>- បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ មានអ្នកចូលរួម **១៤១**នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សេចក្តីណែនាំអំពីការប្រើប្រាស់សៀវភៅបណ្តុះបណ្តាលឆ្លើយតបនិងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ ចំនួន ០១លើក តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួម **៧៥**នាក់ ស្រី **១៦**នាក់។ |

| | |
|---|---|
| ខេត្តកំពង់ធំ | - បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ នៅទីស្ដីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមកិច្ចពិភាក្សាជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) លើគម្រោងសកម្មភាពស្ត្រីដើម្បីចំណាកស្រុកដោយសុវត្ថិភាព។ |
| ខេត្តកោះកុង | - បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី សេចក្ដីណែនាំអំពីការប្រើប្រាស់សៀវភៅបណ្ដុះបណ្ដាលឆ្លើយតបនិងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ ចំនួន ០១លើក តាមប្រព័ន្ធអនឡាញ។<br>- បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ នៅទីស្ដីការក្រសួងមហាផ្ទៃ។ |
| ខេត្តព្រះវិហារ | - បានចូលរួម វគ្គបណ្ដុះបណ្ដាលស្ដីពី ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០១លើក ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយ IOM ។ |
| ខេត្តក្រចេះ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤ ០១លើក |
| ខេត្តកំពត | - លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំប្រចាំខែ ០១លើក មានអ្នកចូលរួម ៣០នាក់ ស្រី ១៥នាក់។ |
| ខេត្តមណ្ឌលគិរី | - បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី បែបបទ និងនិតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប ដែលរៀបចំដោយ គ.ជ.ប.ជ ០១លើក។ |
| ខេត្តរតនគិរី | - តំណាងមន្ទីរកិច្ចការនារី បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញ ស្ដីពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ ០១លើក មានអ្នកចូលរួម ៩០នាក់។ |
| ខេត្តបន្ទាយមានជ័យ | - បានចូលរួមកិច្ចប្រជុំផ្ទៃក្នុង ដើម្បីរៀបចំផែនការអនុវត្តសម្រាប់ឆ្នាំ២០២៤ និងលើកទិសដៅបន្តរបស់មណ្ឌល ចំនួន០២លើក លើការងារចំណាកស្រុកដោយសុវត្ថិភាព ការជួយសង្គ្រោះជនរងគ្រោះ និងងាយរងគ្រោះ ។<br>- ចូលរួមប្រជុំពិភាក្សាស្ដីពី ចំណាកស្រុកដោយសុវត្ថិភាព និងការឆ្លើយតបជនចំណាកស្រុក ជនមាតុភូមិនិវត្តន៍ ០១លើក នៅខេត្តសៀមរាប ។<br>- លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌល បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់បន្ត លើយន្តការបញ្ជូនថ្នាក់ជាតិ ពាក់ព័ន្ធអំពើជួញដូរមនុស្ស ខេត្តសៀមរាប ចំនួន ០១លើក មានសិក្ខាមចូលរួម ៦៣នាក់ ស្រី ៣២នាក់។<br>- លោកស្រី **ស្នងការរងខេត្ត និងមន្ត្រី** ការិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលរួមប្រជុំដោយផ្ទាល់ ០៥លើក និងតាមប្រព័ន្ធអនឡាញ ០១លើក លើខ្លឹមសារ ១-កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ។ ២-កិច្ចប្រជុំ សេចក្ដីណែនាំអំពីការប្រើប្រាស់សៀវភៅបណ្ដុះបណ្ដាលស្ដីពី ការឆ្លើយតបនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ។ ៣-កិច្ចប្រជុំបូកសរុបលទ្ធផលការងារអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ២០២៣។ ៤-កិច្ចប្រជុំត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានអ្នកចូលរួម **២៥៥**នាក់ ស្រី១៤៩នាក់។ |